# ភាពតម្រូវក្នុងការចាក់ថ្នាំបង្ការរោគចំពោះសិស្សនៅសាលារៀនរដ្ឋមេន

សិស្សទាំងអស់ នៅរដ្ឋមេន មិនថារៀនសាលារដ្ឋ ឬសាលាឯកជនឡើយ ត្រូវចាក់ថ្នាំបង្ការជំងឺខាងក្រោម ។

ថ្នាំបង្ការជំងឺសម្រាប់**សិស្សមត្តេយ្យ** ៖

- ថ្នាំបង្ការជំងឺរោគខាន់ស្លាក់ តេតាណុស និង ជំងឺក្អកមាន់ (DTaP) ចំនួន 5 ដង (អាចទទួលតែ 4 ដងក៏បានដែរ បើសិនជាដូសទី4 ត្រូវផ្តល់ជូននៅពេល ឬក្រោយកុមារអាយុគ្រប់ 4 ឆ្នាំ)
- ថ្នាំបង្ការជំងឺស្វិតដៃជើង ចំនួន 4 ដង (ទទួលថ្នាំបង្ការជំងឺស្វិតដៃជើងតែ 3 ដងក៏បានដែរ បើសិនជាដូសទី 3 ត្រូវផ្តល់ជូននៅពេល ឬក្រោយកុមារអាយុគ្រប់ 4 ឆ្នាំ)
- ថ្នាំបង្ការជំងឺកញ្ជ្រឹល ស្រឡទែន ស្អូច (MMR) ចំនួន 2 ដង
- ថ្នាំបង្ការ Varicella (អុតស្វាយ) ចំនួន 2 ដង

ភាពតម្រូវសម្រាប់**ទារកដ្ឋាន** ៖

- ថ្នាំបង្ការជំងឺខាន់ស្លាក់ តេតាណុស ក្អកមាន់ (DTaP) ចំនួន 4 ដង
- ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង ចំនួន 3 ដង
- ថ្នាំបង្ការជំងឺ MMR ចំនួន 1 ដង
- ថ្នាំបង្ការ Varicella (អុតស្វាយ) ចំនួន 1 ដង

បង្ការជំងឺសម្រាប់**សិស្សថ្នាក់ទី** 7 ៖

- ត្រូវទទួលថ្នាំបង្ការជំងឺទាំងអស់ដែលពួកគេត្រូវទទួលពីពេលមុន
- ថ្នាំបង្ការជំងឺតេតាណុស ខាន់ស្លាក់ ក្អកមាន់ (Tdap) ចំនួន 1 ដង
- ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល (MCV4) ចំនួន 1 ដង

បង្ការជំងឺសម្រាប់**សិស្សថ្នាក់ទី** 12 ៖

- ត្រូវទទួលថ្នាំបង្ការជំងឺទាំងអស់ដែលពួកគេត្រូវទទួលពីពេលមុន
- ថ្នាំបង្ការជំងឺ MCV4 ចំនួន 2 ដង (គឺអាចចាក់តែមួយដូសក៏បានដែរ បើសិនជាដូសទី 1 ត្រូវបានផ្តល់ជូននៅពេល ឬក្រោយកុមារមានអាយុគ្រប់ 16 ឆ្នាំ)

ឬ

- មានការលើកលែងជាលក្ខណៈវេជ្ជសាស្ត្រ ដោយមិនបាច់ទទួលថ្នាំបង្ការជំងឺណាមួយ ឬទាំងអស់
- ភស្តុតាងពីមន្ទីរពិសោធន៍អំពីការមានភាពស៊ាំមេរោគក្នុងរាងកាយ ចំពោះជំងឺណាមួយ ឬមានឯកសារបញ្ជាក់ពីគ្រូពេទ្យ ឬពេទ្យថែទាំបឋមផ្សេងទៀត អំពីប្រវត្តិក្នុងការទុកចិត្តបានចំពោះភាពមិនឆ្លងជំងឺ
- ការលើកលែងមិនបាច់ប្រើថ្នាំបង្ការដោយហេតុផលជំនឿ ឬសាសនា គឺទទួលយកបានតែចំពោះសិស្ស IEP ហើយការលើកលែងនេះ ត្រូវបានអនុវត្តនៅមុនថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2021

ព័ត៌មានអំពីការទទួលថ្នាំបង្ការជំងឺនីមួយៗ ត្រូវរួមបញ្ចូលនូវប្រភេទថ្នាំបង្ការ ថ្ងៃខែទទួល និងឈ្មោះពេទ្យ/អ្នកផ្តល់សេវា ។ មកដល់ថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2021 គឺមានការអនុគ្រោះតែចំពោះការលើកលែងមិនបាច់ទទួលថ្នាំបង្ការជំងឺ តាមលក្ខណៈវេជ្ជសាស្ត្រប៉ុណ្ណោះ ដូចដែលបានរៀបរាប់នៅក្នុងខ្លឹមសារច្បាប់ដែលមានចែងក្នុង Title 20-A §6355

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង


នាយកដ្ឋានអប់រំរដ្ឋមេន ការិយាល័យគាំទ្រសាលា និងសិស្ស

អ៊ីម៉េល ៖ DOESchoolandStudentSupports@maine.gov

ការចាក់ថ្នាំបង្ការជំងឺ | នាយកដ្ឋានអប់រំ (maine.gov)



នាយកដ្ឋានសេវាសុខភាព និងពលរដ្ឋ ប្រចាំរដ្ឋមេន,
Maine CDC

នាយកដ្ឋានអប់រំប្រចាំរដ្ឋមេន
ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 14/2/2023